**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ:...............................គ.ម.ក

# លទ្ធផលប្រជុំ
# គណៈកម្មការមូលបត្រកម្ពុជាលើកទី ២៧

នៅរសៀលថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ **ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការមូលបត្រកម្ពុជាលើកទី ២៧ ។ក្នុងកិច្ចប្រជុំគណៈកម្មការមូលបត្រកម្ពុជាលើកទី ២៧ នេះ អង្គប្រជុំ បានពិនិត្យ និងពិភាក្សាលើរបៀបវារៈស្តីពីសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង **(IPO)** របស់ ក្រុមហ៊ុនហ្គ្រេនធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (Grand Twins International (Cambodia) Plc.) ដែលជាក្រុមហ៊ុនវាយនភណ្ឌកាត់ដេរ និងច្នៃម៉ូតសំលៀកបំពាក់កីឡាគ្រប់ប្រភេទ ។ ក្រុមហ៊ុន ហ្គ្រេនធ្វីន ជាក្រុមហ៊ុនវិនិយោគពីបរទេស ដែលបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មពីឆ្នាំ២០០៧ មក និងបានផ្គត់ផ្គង់សំលៀកបំពាក់កីឡាសម្រាប់ម៉ាកសំលៀកបំពាក់ល្បីៗឱ្យក្រុមហ៊ុន **Adidas Group** មានដូចជាសំលៀកបំពាក់ម៉ាក **Adidas**, ម៉ាក **Reebook**, និងម៉ាក **Taylor Made** (អាវយឺតសម្រាប់កីឡាវាយកូនហ្គោល) ។ ក្រៅពីការផ្គត់ផ្គង់សំលៀកបំពាក់កីឡាឱ្យក្រុមហ៊ុន **Adidas Group** ដែលជាអតិថិជនសំខាន់របស់ខ្លួន ក្រុមហ៊ុន ហ្គ្រេនធ្វីន ផ្គត់ផ្គង់សំលៀកបំពាក់កីឡាឡើងភ្នំ រត់ប្រណាំង និង ជិះស្គី ម៉ាក **Salomon**, និងផ្គត់ផ្គងសំលៀកបំពាក់កីឡាម៉ាក **New Balance**, ម៉ាក **Kohl's** និង ម៉ាក **Li & Fong** ផងដែរ ។ ទីផ្សារចម្បងរបស់ក្រុមហ៊ុន ហ្គ្រេនធ្វីន គឺ ទីផ្សារសហភាពអឺរ៉ុប និង អាមេរិក ។

បន្ទាប់ពីអង្គប្រជុំបានពិនិត្យទៅលើខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាន សម្រាប់ធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ និងរបាយការណ៍របស់មន្ត្រីជំនាញ ព្រមទាំងបានពិភាក្សា និងវិភាគយ៉ាងល្អិតល្អន់ លើសាវតាអាជីវកម្មរបស់ក្រុមហ៊ុន លើទិដ្ឋភាពហិរញ្ញវត្ថុនិងចំណេញភាព លើទិដ្ឋភាពអភិបាលកិច្ចសាជីវកម្ម ព្រមទាំងលើទិដ្ឋភាពគ្រប់គ្រងហានិភ័យរួចមក អង្គប្រជុំបានសម្រេច **អនុញ្ញាតនិងចុះបញ្ជីជាគោលការណ៍** នូវឯកសារផ្តល់ព័ត៌មានរបស់ក្រុមហ៊ុនហ្គ្រេនធ្វីន និងបានណែនាំឱ្យមន្ត្រីជំនាញបន្តការងារដែលនៅសេសសល់លើផ្នែកនីតិវិធី និងបែបបទផ្សេងៗ ដើម្បីឱ្យក្រុមហ៊ុនបន្តនីតិវិធីធ្វើប៊ុកបៀលឌីង **(Book-building)** និងឈានទៅធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈទៅតាមច្បាប់ និងបទប្បញ្ញត្តិ ជាធរមាន ។

ជាមួយគ្នានេះ អង្គប្រជុំក៏បានពិនិត្យ និងពិភាក្សាលើរបៀបវារៈទី២ ដោយសម្រេចអនុញ្ញាតលើសំណើរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា **(CSX)** ក្នុងការបន្តបញ្ចុះថ្លៃសេវាជួញដូរមូលបត្រ, ថ្លៃសេវាផាត់ទាត់និងទូទាត់មូលបត្រ, និងថ្លៃសេវាផ្ទេរមូលបត្ររវាងគណនី ចំនួន ៥០% សម្រាប់ឆ្នាំ២០១៤ បន្តទៀត ក្នុងគោលបំណងលើកទឹកចិត្តដល់ការជួញដូរមូលបត្រក្នុងទីផ្សារ ។

អង្គប្រជុំបានបញ្ចប់នៅម៉ោង ៥ និង ៤៥ នាទីល្ងាច ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងបន្តកិច្ចប្រជុំលើកទី ២៨ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ លើរបៀបវារៈ ដែលនៅសេសសល់មិនទាន់បានពិនិត្យ និងពិភាក្សា ។

**គណៈកម្មការមូលបត្រកម្ពុជា**

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622